# ដំណើរការប្រជុំនៅ ក្រុមហ៊ុន CheckinMe

## ១. គោលបំណង

ដំណើរការនេះត្រូវបានរៀបចំឡើង ដើម្បីឲ្យគ្រប់ការប្រជុំនៅក្រុមហ៊ុន CheckinMe ប្រព្រឹត្តទៅ ដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ និងចំណេញពេលវេលា ។ បញ្ហាទាំងឡាយ ត្រូវបានលើក និងដោះស្រាយទាន់ពេលវេលា ដើម្បីការរីកចម្រើន របស់ក្រុមហ៊ុន ។

## ២. ប្រភេទនៃការប្រជុំ

ក្រុមហ៊ុនទេស CheckinMe ចែកការប្រជុំជាពីរប្រភេទ គឺ ៖

ក- ការប្រជុំគណៈកម្មាធិការប្រតិបត្តិ ដែលមាន អគ្គនាយក ជាប្រធានអង្គប្រជុំ និងប្រធានផ្នែកទាំងអស់ ជាសមាជិកអង្គប្រជុំ ហើយប្រធានផ្នែក ឬ បុគ្គលិកផ្នែកធនធានមនុស្ស និងរដ្ឋបាល ជាលេខាធិការអង្គប្រជុំ ។ ការប្រជុំ អាចប្រព្រឹត្តទៅ ១ សប្តាហ៍ម្តង រៀងរាល់ថ្ងៃច័ន្ទ ។

ខ- ការប្រជុំតាមផ្នែកជំនាញ ដែលមានប្រធានផ្នែក ជាប្រធានអង្គប្រជុំ និងអនុប្រធានផ្នែក និងបុគ្គលិកទាំងអស់ ជាសមាជិកអង្គប្រជុំ ។ ប្រធានអង្គប្រជុំ អាចចាត់បុគ្គលិកណាម្នាក់ ជាលេខាធិការអង្គប្រជុំ ។ ការប្រជុំ ជាធម្មតាអាចប្រព្រឹត្តទៅ ១ ខែម្តង ។ ក្នុងករណីចាំបាច់ណាមួយ តម្រូវឲ្យមានការប្រជុំវិសមញ្ញ ដើម្បីពិភាក្សាទាន់ពេលវេលា។

## ៣. របៀបវារៈអង្គប្រជុំ

- បើកអង្គប្រជុំ និងគោលបំណង
- តាមដានផែនការសកម្មភាព និងការងារកន្លងមក
- ផ្សេងៗ និងសំណូមពរ
- ផែនការសកម្មភាព ដែលត្រូវអនុវត្តបន្ត
- បិទអង្គប្រជុំ

## ៤. ដំណើរការអង្គប្រជុំ

### ក- បើកអង្គប្រជុំ និងគោលបំណង

នៅពេលចាប់ផ្តើមប្រជុំ ប្រធានអង្គប្រជុំ ត្រូវប្រកាសបើកអង្គប្រជុំ និងរៀបរាប់អំពីគោលបំណងនៃការប្រជុំ ឲ្យបានច្បាស់លាស់ ទៅសមាជិកទាំងអស់ ។

**ខ- តាមដានផែនការសកម្មភាព និងការងារកន្លងមក**

នៅក្នុងដំណាក់កាលនេះ ប្រធានអង្គប្រជុំ ត្រូវឲ្យសមាជិកតាមផ្នែកនីមួយៗ រាយការណ៍ ពីផែនការសកម្មភាព ដែលបានដាក់ឲ្យអនុវត្ត នៅពេលប្រជុំលើកមុន ។

**គ- ផ្សេងៗ និងសំណូមពរ**

ប្រធានអង្គប្រជុំ ត្រូវឲ្យសមាជិកតាមផ្នែកនីមួយៗ លើកពីបញ្ហាតាមផ្នែករៀងៗខ្លួន ឬបញ្ហាពាក់ព័ន្ធផ្នែកផ្សេង ដើម្បីដាក់ជូនអង្គប្រជុំទាំងមូលពិភាក្សា និងដោះស្រាយ ។ ក្នុងដំណាក់កាលនេះ ប្រធានអង្គប្រជុំត្រូវចេះសម្របសម្រួល និងសម្រេចចិត្ត ឲ្យបានច្បាស់លាស់ ។

**ឃ- ផែនការសកម្មភាព ដែលត្រូវអនុវត្តបន្ត**

បន្ទាប់ពីដោះស្រាយបញ្ហា និងសំណូមពររួចរាល់ហើយ ប្រធានអង្គប្រជុំ ត្រូវដាក់ផែនការសកម្មភាពដែលត្រូវអនុវត្តបន្ត ទៅតាមផ្នែកជំនាញនីមួយៗ ដោយយោងតាម ៖

- បញ្ហា និងដំណោះស្រាយខាងលើ
- ចំណុចខ្វះខាត តាមផ្នែកនីមួយៗ
- គំនិតថ្មីៗ ផ្សេងទៀត ដែលត្រូវអភិវឌ្ឍ ។ល។

**ង- បិទអង្គប្រជុំ**

ប្រធានអង្គប្រជុំ ប្រកាសបិទអង្គប្រជុំ

( សូមមើលទម្រង់គម្រូ កំណត់ហេតុអង្គប្រជុំ ដូចភ្ជាប់មកជាមួយ )